សម្រាប់ការចុះផ្សាយបន្ទាន់ ៖ ថ្ងៃសុក្រទី ២៨ មេសា ២០២០
លេខទំនាក់ទំនងសាលាក្រុង 781-286-8111

# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ២៨ មេសា ២០២០

## *លោកអភិបាល Arrigo បង្កើតមូលនិធិរៃអង្គាសប្រាក់ និង ប្រកាសពីកញ្ចប់ជំនួយសង្គ្រោះ COVID-19 ចំនួន ១,៧ លានដុល្លារ*

*ថវិកានឹងយកទៅទ្រទ្រង់លើផ្នែកអប់រំ ធនធានមនុស្ស និងស្តារសេដ្ឋកិច្ចឡើងវិញ*

## *ការផ្តល់ជំនួយសង្គ្រោះបន្ទាន់សម្រាប់អាជីវកម្មខ្នាតតូច*

ថ្ងៃទី ២៨ មេសា ២០២០ – ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។ នៅថ្ងៃនេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្តល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 សរុបចំនួន ១០៨៧ ករណី នៅក្នុងក្រុង Revere។

ថ្ងៃនេះ លោកអភិបាល Arrigo បានប្រកាសកម្មវិធីរៃអង្គាសថវិកា "Raise Up Revere Fund" ដើម្បីជាផ្នែកមួយ ជួយស្រោចស្រង់ដល់ស្ថានភាពរាតត្បាតនៃជំងឺ COVID-19។ ថវិកាដើមនៅពេលនេះ សរុបមាន ១,៧ លានដុល្លារ ដែលបានមកពីមូលនិធិអភិវឌ្ឍន៍សហគមន៍ (CDBG) និងអំណោយពីស្ថាបនឯកជន។ ការផ្តល់ជំនួយសង្គ្រោះបន្ទាន់នេះ នឹងផ្តោតលើការឆ្លើយតបតាមតម្រូវការយូរអង្វែងរបស់គ្រួសារនីមួយៗ និងអាជីវកម្មខ្នាតតូចដែលមាននៅក្នុងក្រុង Revere។ កម្មវិធីដែលផ្តល់ថវិកាតាមរយៈកញ្ចប់ជំនួយនេះ នឹងត្រូវបានណែនាំជាមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការ។

## *ការរៃអង្គាសប្រាក់មូលនិធិ*

លោកអភិបាល Arrigo បានបង្កើតមូលនិធិរៃអង្គាសប្រាក់ "Raise Up Revere Fund" ដើម្បីការពារដល់អាជីវកម្មខ្នាតតូច និងសហគមន៍ នៅតំបន់ដែលមានតម្រូវការឲ្យជួយសង្គ្រោះ។ កម្មវិធីនេះ នឹងផ្តល់ការយកចិត្តទុកដាក់ខ្ពស់ លើការជ្រោមជ្រែងដល់យុវជន គ្រួសារ និងម្ចាស់ជំនួញខ្នាតតូច។ មូលនិធិនេះ ត្រូវបានផ្តើមជាដំបូងជាមួយទឹកប្រាក់ ២៥០ ០០០

ដុល្លារ ពីជនសប្បុរសមិនបង្ហាញមុខ ដែលមានគោលបំណងចង់ធ្វើការជាមួយដៃគូដទៃ  និងរៃអង្គាសបន្ថែមទៀតពីស្ថាបនឯកជនផ្សេងទៀត។ សម្រាប់ព័ត៌មានបន្ថែម និងរបៀបនៃការចូលរួមបរិច្ចាគ នឹងមានលម្អិតនៅសប្តាហ៍ក្រោយ។

## *កម្មវិធីផ្តល់ជំនួយសង្គ្រោះបន្ទាន់សម្រាប់អាជីវកម្មខ្នាតតូច–ពាក្យស្នើសុំ មានចាប់ពីថ្ងៃនេះតទៅ*

កម្មវិធីផ្តល់ជំនួយបន្ទាន់សម្រាប់អាជីវកម្មខ្នាតតូចរបស់សាលាក្រុង នឹងផ្តល់ការសង្គ្រោះបន្ទាន់ដល់អាជីវកម្មខ្នាតតូចណាដែលរងផលប៉ះពាល់ដោយសារជំងឺ COVID-19។ ចំនួននៃជំនួយនោះ អាចមានរហូតដល់ ១០ ០០០ដុល្លារ សម្រាប់អាជីវកម្មមួយ។ ឯចំនួនដែលនឹងផ្តល់ដល់ផ្នែកនេះ សរុបមាន ២៨០ ០០០ ដុល្លារ។ ពាក្យស្នើសុំ និងលក្ខណៈវិនិច្ឆ័យមាននៅលើ revere.org។ មូលប្បទានប័ត្រ(សែគ) ដំបូងនឹងត្រូវផ្តល់ជូនដល់អាជីវកម្មចាប់ពីសប្តាហ៍ក្រោយ។ ពាក្យសុំនានា នឹងត្រូវបានពិនិត្យ និងផ្តល់សេចក្តីសម្រេច ក្នុងរយៈពេល៣ថ្ងៃនៃម៉ោងធ្វើការ ហើយបេក្ខជនដែលទទួលការយល់ព្រម នឹងទទួលបានកញ្ចប់ថវិកា ក្នុងរយៈពេលពី ៧-១០ ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីសម្រេច។ អ្នកអាចយកមូលនិធិជំនួយនេះទៅធ្វើជាដើមទុកក្នុងការចំណាយនានាដូចជា ការឲ្យថ្លៃឈ្នួលបុគ្គលិក ទូទាត់បំណុល និងបង់ថ្លៃឧបករណ៍ប្រើប្រាស់ ក៏ដូចជាការចំណាយផ្សេងៗ។

## *កម្មវិធីផ្តល់ជំនួយផ្នែកអាហារូបត្ថម្ភ*

ដើម្បីឆ្លើយតបតាមតម្រូវការរបស់ប្រជាជនដែលប្រឈមមុខនឹងបញ្ហាស្បៀងអាហារដោយសារការរាតត្បាតនៃជំងឺ COVID-19 សមាគមន៍ CDBG បានបន្ថែមមូលនិធិចំនួន ៨០ ០០០ ដុល្លារ ដើម្បីដំណើរការកម្មវិធីចែកជូនគ្រឿងទេស និងសេវាកម្មចែកជូនអាហារ។ ព័ត៌មានលម្អិត នឹងមានផ្សាយជូនក្នុងពេលឆាប់ៗខាងមុខ៕

###